F06 - 23

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ



# មេរៀនទី៥

## អំពី

# បង្កើត និងអភិវឌ្ឍន៍ ស.ក.ប.ធ

រៀបចំដោយៈ ក្រសួងធនធានទឹក និងឧតុនិយម

ភ្នំពេញ, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០០៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ 151 ធទឧ

ទ.ឯ.ខ.ក AIDOC
Code: 157-004
Date:
Donated by:

# ប្រកាស

## ស្តីពីការដាក់អោយប្រើប្រាស់ជាផ្លូវការនូវឯកសារមេរៀនជាមូលដ្ឋានចំនួន ០៧ ដើម្បីអនុវត្តការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមពីអ្នកទទួលផល និងកិច្ចអភិវឌ្ឍន៍ (PIMD) ក្នុងទិសដៅបង្កើត និងកិច្ចអភិវឌ្ឍន៍សហគមន៍កសិករប្រើប្រាស់ទឹក (ស.ក.ប.ទ) ក្នុងក្របខ័ណ្ឌទូទាំងប្រទេស

✧✧✧✧✧✧✧✧✧✧✧✧✧✧

## រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញសារាចរលេខ ០១ សរ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញប្រកាសលេខ ៣០៦ ប្រក.ធទឧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០០ របស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញលិខិតលេខ ០៥៨ ធទឧ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០២ របស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញសេចក្តីសំរេចលេខ ១១៨ ធទឧ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០២ របស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញការចាំបាច់របស់ក្រសួងធនធានទឹក និងឧតុនិយម

លេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារលេខ : (៨៥៥) ២៣.៤២៦ ៣៤៥ / (៨៥៥) ២៣.៧២៥ ៩៨៩
# 47 Preah Norodom B V D. Phnom Penh. Fax/Phone: (855)23 426 345 / (855)23.725 989 E-mail: planning@cttnet.com.kh

# ស ំ រេ ច

**ប្រការ ១:**

អនុញ្ញាតដាក់អោយប្រើប្រាស់ជាផ្លូវការនូវឯកសារមេរៀនជាមូលដ្ឋានចំនួន ០៧ ដើម្បីអនុវត្តការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមពីអ្នកទទួលផល និងកិច្ចអភិវឌ្ឍន៍ (PIMD) ក្នុងទិសដៅបង្កើត និងអភិវឌ្ឍន៍សហគមន៍កសិករប្រើប្រាស់ទឹក (ស.ក.ប.ទ) ដូចមានក្នុងឧបសម្ព័ន្ធទី១, ២, ៣, ៤, ៥ ,៦ និងទី៧ នៃប្រកាសនេះជាភាសាខ្មែរ និងភាសាអង់គ្លេស។

**ប្រការ ២:**

គ្រប់អង្គភាពចំណុះក្រសួងធនធានទឹក និងឧតុនិយម ត្រូវប្រឹក្សាជាប្រចាំជាមួយក្រសួងធនធានទឹក និងឧតុនិយម (នាយកដ្ឋានធារាសាស្ត្រកសិកម្ម) ដើម្បីប្រើប្រាស់ឯកសារនេះអោយមានប្រសិទ្ធិភាពខ្ពស់ និងចំទិសដៅ។

**ប្រការ ៣:**

គ្រប់អង្គភាពចំណុះក្រសួងធនធានទឹក និងឧតុនិយម ត្រូវសហការប្រកបដោយស្មារតីយកចិត្តទុកដាក់ផ្សព្វផ្សាយដល់គ្រប់ស្រទាប់កសិករប្រើប្រាស់ទឹកដែលមានទីតាំងជាប់ប្រព័ន្ធធារាសាស្ត្រទាំងអស់នៅទូទាំងប្រទេសកម្ពុជា រួចត្រូវរាយការណ៍ពីប្រសិទ្ធិភាព និងលទ្ធផលការងារជូនក្រសួងធនធានទឹក និងឧតុនិយម ជាប្រចាំ។

**ប្រការ ៤:**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥:**

អគ្គនាយក អគ្គាធិការ និងគ្រប់អង្គភាពចំណុះក្រសួងធនធានទឹក និងឧតុនិយម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី 30 ខែ 7 ឆ្នាំ ២០០៣

**រដ្ឋមន្ត្រី**

លឹម_គានហោ

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយម
- ដូចក្នុងប្រការ ៥
- ឯកសារ-កាលប្បវត្តិ






សិក្ខាសាលាជាតិស្តីពី ស.ក.ប.ទ និង PIMD នៅសណ្ឋាគារ Le Royal ទីក្រុងភ្នំពេញ



ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រាយការណ៍ជូនជនរួមជាតិនូវលទ្ធផលអភិវឌ្ឍន៍ និងគ្រប់គ្រងវិស័យធនធានទឹកប្រកបដោយនិរន្តរភាពរបស់ព្រះរាជាណាចក្រកម្ពុជា




ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម
ថ្លែងសន្ទរកថាបើកសិក្ខាសាលា ស្តីពី ស.ក.ប.ទ និង PIMD ដោយសង្កត់ធ្ងន់
លើការអនុវត្តន៍អោយមានប្រសិទ្ធិភាពខ្ពស់លើផែនការសកម្មភាពរយៈពេលវែង
ស្តីពី ស.ក.ប.ទ និង PIMD របស់ក្រសួងធនធានទឹក និងឧតុនិយម



ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ជំរាបជូនសមាជិករាជរដ្ឋាភិបាល អង្គការ NGOs និងស្ថានទូតប្រទេសនានា ប្រចាំប្រទេសកម្ពុជា ADB WB និងក្រសួងពាក់ព័ន្ធ នូវគោលបំណងរបស់គំរោងអភិវឌ្ឍន៍ និងគ្រប់គ្រងវិស័យប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព ក្នុងគំរោងអភិវឌ្ឍន៍ភាគខាងលិចរាជធានីភ្នំពេញ ។




World Bank គាំទ្រ និង សរសើរ នូវលទ្ធផល
ការងាររបស់ក្រសួងធនធានទឹក និងឧតុនិយម
លើការរៀបចំ ស.ក.ប.ទ និងអនុវត្ត PIMD



កិច្ចប្រជុំបច្ចេទេសដើម្បីផ្លាស់ប្តូរយោបល់ និងពិភាកក្សារកថវិកាដើម្បីគាំទ្រកម្មវិធី PIMD និង ស.ក.ប.ទ របស់ប្រទេសកម្ពុជា
នៅប្រទេសជប៉ុន IWMI-HQ Colombo- Sri Lanka ប្រទេសចិន និង ប្រទេសស៊ុយអ៊ែត



វគ្គបណ្ដុះបណ្ដាលស្ដីពី IMT (Irrigation Management Transfer) នៅខេត្តសៀមរាប
រៀបចំឡើងដោយក្រសួងធនធានទឹក និងឧតុនិយម និងស្ថានទូតសហព័ន្ធអាឡឺម៉ង់ប្រចាំប្រទេសកម្ពុជា



ការរៀបចំផែនការការងារប្រតិបត្តិ និងរយៈពេលមធ្យម
លើការងារ ស.ក.ប.ទ និង PIMD ក្នុងកម្មវិធី Seila







សកម្មភាពត្រួតពិនិត្យ និងវាយតំលៃ លើការងារ ស.ក.ប.ទ និង PIMD


[illegible]
[illegible] PIMD









ប្រព័ន្ធធារាសាស្ត្រទំនប់អូរត្រែងត្រូវបានធ្វើការជួសជុលដោយក្រសួងធនធានទឹក និងឧតុនិយម ក្រោមគំរោងឥណទានកម្មវិធី ADB 1445 CAM SF ដើម្បីអនុវត្តការរៀបចំ ស.ក.ប.ទ និងគោលនយោបាយ PIMD គំរូជូនទូទាំងប្រទេស



ប្រព័ន្ធធារាសាស្ត្រកប់សេះក្នុងពេលកំពុងជួសជុល
និងក្រោយពេលជួសជុលហើយ ក្នុងគោលបំណងអនុវត្តនូវការរៀបចំ ស.ក.ប.ទ និង PIMD



វគ្គបណ្តុះបណ្តាលស្តីពី PIMD និង ស.ក.ប.ទ នៅនាយកដ្ឋានធារាសាស្ត្រកសិកម្មក្រសួងធនធានទឹក និងឧតុនិយម


ការបណ្តុះបណ្តាលស្តីពី ស.ក.ប.ទ និង PIMD ជូនដល់គ្រូបង្គោល ដែលអញ្ជើញមកពីខេត្តទាំង១១
រៀបចំដោយនាយកដ្ឋានធារាសាស្ត្រកសិកម្ម ក្រសួងធនធានទឹក និងឧតុនិយម



ការចុះពង្រឹងសមត្ថភាពរបស់ ស.ក.ប.ទ ដែលបានរៀបចំ
រួចហើយលើការងារ ស.ក.ប.ទ និង PIMD

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី..5.....នៃប្រកាសលេខ..151....ប្រក.ធទឧ

ចុះថ្ងៃទី.....30.........ខែ......07...........ឆ្នាំ២០០៣

# មេរៀនទី៥

# អំពី

# បង្កើត និងអភិវឌ្ឍន៍ ស.ក.ប.ន

រៀបចំដោយៈ ក្រសួងធនធានទឹក និងឧតុនិយម

ភ្នំពេញ, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០០៣

# មា តិ កា

**ទំព័រ**


មេរៀនទី៥ ........................................................................................................ ១៣១

១- សារឡើងវិញមេរៀនទី៤ ........................................................................... ១៣១

២- ទស្សនៈរួមនៃមេរៀនទី៥ .......................................................................... ១៣១

៣- ការអនុគ្រោះសំរាប់កសិករដើម្បីគាំទ្រ PIMD ....................................... ១៣២

៤- មុខងាររបស់សមាជិកក្រុមទ្រទ្រង់ ស.ក.ប.ទ ......................................... ១៣២

៥- ផែនការ ការងារសំរាប់ក្រុមទ្រទ្រង់ ស.ក.ប.ទ ....................................... ១៣៣

៦- ពិនិត្យឡើងវិញអំពីគោលការណ៍សំខាន់បួនយ៉ាងរបស់ PIMD ..................... ១៣៣

៧- តួនាទីរបស់អ្នកសំរបសំរួល និងវិធីសាស្ត្រទាក់ទងដោយមានប្រសិទ្ធិភាព ......................... ១៣៥

៨- ជំហានក្នុងការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក ..................................... ១៣៥

៩- សវនកម្មការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ................................................ ១៤២

១០- លំហាត់ជាក្រុមសំរាប់មេរៀនទី៥ វគ្គទី១ ................................................. ១៤៣

១១- សង្ខេបមេរៀនទី៥ វគ្គទី១ ..................................................................... ១៤៤

# មេរៀនទី ៥

## ការបង្កើត និងអភិវឌ្ឍន៍សហគមន៍កសិករប្រើប្រាស់ទឹក

## វគ្គទី ១ : ការបណ្ដុះបណ្ដាលក្នុងថ្នាក់រៀន

## ១. សារឡើងវិញមេរៀនទី ៤

១- អ្នករាយការណ៍បង្ហាញការសង្ខេបមេរៀនទី **៤** វគ្គទី **១** ។ បន្ទាប់មកមានសំណួរ និងចម្លើយ ដើម្បីបំភ្លឺ

**២-** សិក្ខាកាមបង្ហាញលទ្ធផលការអនុវត្តជាក្រុមក្នុងមេរៀនទី **៤** វគ្គទី **២** ។ បន្ទាប់មានការពិភាក្សា ។

## ២. ទស្សនៈរួមនៃមេរៀនទី ៥

គោលបំណងនៃមេរៀនទី5គឺផ្ដល់ឱ្យសិក្ខាកាមនូវការយល់ដឹងយ៉ាងច្បាស់ និងជួយឱ្យពួកគេសំរេចកិច្ចព្រមព្រៀង អំពីអ្វីដែលត្រូវធ្វើដោយក្រុមទ្រទ្រង់ ស.ក.ប.ទ នៅកំរិតថ្នាក់ខេត្ត និងប្រពន្ធ័ធារាសាស្ត្រដើម្បីបង្កើត ស.ក.ប.ទ ដ៏រឹងមាំនិងកសាងសមត្ថភាព ស.ក.ប.ទ។ មេរៀននេះផ្ដល់ការណែនាំអំពី តើនរណា ត្រូវធ្វើអ្វី ធ្វើនៅពេលណា និងធ្វើដូចម្ដេចនៅថ្នាក់ខេត្ត និងប្រពន្ធ័ធារាសាស្ត្រ។ មេរៀនទី៥ ក៏ផ្ដល់ឱ្យសិក្ខាកាមដែលនឹងមានមុខងារនៅថ្នាក់ខេត្តនូវចំណេះដឹងចាំបាច់ដើម្បីអាចដំណើរការដ៏មានប្រសិទ្ធិភាពនិងណែនាំអំពីជំនាញដើម្បីអភិវឌ្ឍន៍តួនាទីថ្មីរបស់ពួកគេជាអ្នកសំរបសំរួលនិងជាអ្នកផ្ដល់ការគាំទ្រដល់ ស.ក.ប.ទ ថ្មី ។

***<u>មេរៀនទី ៥ នឹងបង្កើតនូវលទ្ធផលដូចខាងក្រោមៈ</u>***

១-សិក្ខាកាមនឹងយល់ដឹងយ៉ាងច្បាស់នូវមុខងារសំខាន់ៗរបស់អង្គការផ្សេងៗនៅថ្នាក់ជាតិ និងថ្នាក់ប្រពន្ធ័ធារាសាស្ត្រ ក្នុងការអនុមត័ ការរៀបផែនការ និងការអនុវត្តន៍ PIMD ជាពិសេសក្រុមទ្រទ្រង់ ស.ក.ប.ទ

២- កំណត់សំគាល់ទស្សនៈទានដែលរៀបចំដោយទីភ្នាក់ងារនិមួយៗដែលពាក់ពន្ធ័ និងថ្នាក់ជាតិអំពីរបៀបដែលភ្នាក់ងារនឹងរៀបចំការអនុគ្រោះសមស្រប និងវិធានការដោយគណនីភាពដើម្បីធានាថាបុគ្គលិករបស់ខ្លួនធ្វើ ការងារ យ៉ាងមានប្រសិទ្ធិភាពលើ PIMD ។

៣- ផែនការលំអិតអំពីរបៀបរបស់ក្រុមទ្រទ្រង់ ស.ក.ប.ទ នឹងរកអ្នកតំណាងកសិករជាបណ្ដោះអាសន្នដើម្បីជួយដំណើរការរៀបចំ។

៤- ព្រាងរបៀបវារៈសំរាប់កិច្ចប្រជុំសំខាន់ៗជាមួយកសិករដើម្បីរៀបចំ ស.ក.ប.ទ។

៥- ព្រាងផែនការ ការងាររយៈពេលពីរឆ្នាំសំរាប់ក្រុមទ្រទ្រង់ ស.ក.ប.ទ

៦- សង្ខេបការពិភាក្សាមេរៀន និងលទ្ធផលលំហាត់។

៧- រាយការណ៍អំពីលទ្ធផលការអនុវត្តន៍ជាក្រុម ។

## ៣.　　ការអនុគ្រោះសំរាប់កសិករដើម្បីគាំទ្រ PIMD

នៅពេលដំបូងកសិករប្រហែលជាមិនយល់តើ PIMD ជាអ្វី ហើយតើវានឹងជួយពួកគេដូចម្តេចទេ។ ជាសំខាន់គឺថាក្រុមទ្រទ្រង់ ស.ក.ប.ទ ត្រូវជួយឱ្យកសិករយល់អំពី PIMD ហើយតើវាអាចជួយកសិករដូចម្តេច។ វាមានសារៈប្រយោជន៍ជាទីបំផុតក្នុងការរៀបចំទស្សនៈកិច្ចសិក្សាមួយសំរាប់អ្នកតំណាងកសិករឱ្យ ទៅពិនិត្យមើលប្រពន្ធ័ធារាសាស្ត្រណាមួយដែលបានអនុវត្ត PIMDរួចជាស្រេចដោយទទួលបានលទ្ធផល យ៉ាងល្អ ។

<u>***ខាងក្រោមនេះគឺជាហេតុផលដែលកសិករគួរដឹកនាំគាំទ្រ PIMD :***</u>

១- វាផ្តល់ឱ្យកសិករអាចត្រួតពិនិត្យលើប្រពន្ធ័ធារាសាស្ត្ររបស់ខ្លួន និងពីរបៀបផ្តល់សេវាកម្មប្រព័ន្ធធារាសាស្ត្រ

២-វាអាចកែលំអររបៀបចែកចាយទឹកតាមរយៈការកំណត់ក្រុមនៃគោលបំណងសេវាកម្មប្រព័ន្ធធារាសាស្ត្រការង្កើតបទបញ្ញតិថ្មី និងពង្រឹងយន្តការ ។ វិធីសាស្ត្រនេះនឹងកាត់បន្ថយជំលោះពីបញ្ហាទឹកដែលកើតឡើង ។

៣- វានឹងអាចកែលំអរគុណភាពការថែទាំសំណង់ប្រព័ន្ធធារាសាស្ត្រ ។

៤- វានឹងបង្កើតឱ្យមានកិច្ចសហប្រតិបត្តិការនិងការសំរបសំរួលល្អជាងមុនសំរាប់កសិករសំរាប់កសិករប្រើប្រាស់ទឹកសំរាប់កសិកម្ម និងទីផ្សារ ។

៥- តាមរយៈកិច្ចសហប្រតិបត្តិការលើវិស័យទឹកវាផ្តល់ជាវេទិការមួយដើម្បីធ្វើការកែលំអរផលិតភាពកសិកម្ម និងផលចំណេញ ។

៦- វាអាចជួយកសិករឱ្យកាត់បន្ថយថ្លៃដើមទុនកសិកម្ម តាមរយៈការទិញដុំជាក្រុម១តាមរយៈ ស.ក.ប.ទ

៧-កសិករណាដែលរៀបចំធ្វើសហប្រតិបត្តិការដើម្បីការគ្រប់គ្រងទឹកបន្ទាប់មកអាចធ្វើសហប្រតិបត្តិការដើម្បី អភិវឌ្ឍន៏ កសិ-ពាណិជ្ជកម្ម និងទីផ្សារជាក្រុម ។

សង្ឃឹមថាការវាយតម្លៃជនបទដោយមានការចូលរួម និងការរៀបចំពង្រាយផែនការសេវាកម្មធារាសាស្ត្រក្នុងមេរៀនទី5 នឹងលើកកំពស់ការយល់ដឹងរបស់កសិករអំពីប្រយោជន៏នៃការបង្កើតសហគមន៏កសិករប្រើប្រាស់ទឹក ។ សិក្ខាកាមក្នុងមេរៀននេះនឹងពិភាក្សាអំពីការអនុគ្រោះដែលមានស្រាប់តាមសភាពពិតក្នុងតំបន់របស់ខ្លួន និងអ្វីដែលត្រូវធ្វើដើម្បីបង្កើនការអនុវត្ត និងការដឹកនាំរបស់កសិករដើម្បីគាំទ្រការបង្កើត និងអភិវឌ្ឍសហគមន៏កសិករប្រើប្រាស់ទឹក (ស.ក.ប.ទ ) ដ៏សកម្ម ។

## ៤.　　មុខងាររបស់សមាជិកក្រុមទ្រទ្រង់ ស.ក.ប.ទ

ក្រុមទ្រទ្រង់ ស.ក.ប.ទ គួរមានយ៉ាងហោចណាស់សមាជិកពីរនាក់មកពីការិយាល័យខេត្តរបស់មន្ទីរធនធានទឹក និងឧតុនិយម គ្រូបង្គោលថ្នាក់ស្រុកមកពីមន្ទីរធនធានទឹក និងឧតុនិយម បុគ្គលិកម្នាក់ឬពីរនាក់ដែលម្នាក់១មកពីការិយាល័យខេត្តរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអភិវឌ្ឍន៏ជនបទ និងសមាជិក

ដ៏ទៃទៀតបើសិនត្រូវការ។ ក្រុមនេះគួរជួបប្រជុំគ្នា ហើយពិភាក្សាអំពីតួនាទី សមាជិកម្នាក់ៗ ដូចជាការរៀបចំសេចក្តីព្រៀងផែនការការងារ រៀបចំកិច្ចប្រជុំ រៀបចំពេលកសាងសមត្ថភាព រៀបចំសកម្មភាពផ្សព្វផ្សាយកសិកម្ម រៀបចំយុទ្ធនាការផ្សព្វផ្សាយពត៌មាន និងរៀបចំកិច្ចប្រជុំជាមួយមន្ត្រីរដ្ឋបាលមូលដ្ឋាន ។ល។

## ៥. ផែនការ ការងារសំរាប់ក្រុមទ្រទ្រង់ ស.ក.ប.ទ

មុនពេលចាប់ផ្តើមអនុវត្តការងារហ្វឹងកន្លែង ត្រូវរៀបចំ ស.ក.ប.ទ ហើយត្រូវកសាងសមត្ថភាពដល់ពួកគេ ក្រុមទ្រទ្រង់ ស.ក.ប.ទ និមួយៗគួរជួបជុំគ្នាដើម្បីរៀបចំផែនការការងារប្រចាំឆ្នាំមួយ ហើយបន្ទាប់មកផែនការនោះត្រូវពិនិត្យឡើងវិញដោយសមាជិកម្នាក់របស់លេខាធិការដ្ឋានជាតិ។ គួររៀបចំការនេះ ឱ្យបានឆាប់ក្នុងដើមឆ្នាំ ដើម្បីអាចឱ្យលេខាធិការដ្ឋានស្វែងរកមូលនិធិ និងចាត់តាំងបុគ្គលិកដើម្បីអនុវត្តជាមុនដើម្បីចៀសវាងភាពយឺតយ៉ាវ។

## ៦. ពិនិត្យឡើងវិញអំពីគោលការណ៍សំខាន់បួនយ៉ាងរបស់ PIMD

កម្មវិធីរបស់ PIMD នឹងទទួលបានជោគជ័យប្រសិនបើ ស.ក.ប.ទ អាចមានសមត្ថភាពគ្រប់គ្រងនិងផ្តល់ហិរញ្ញប្បទានប្រពន្ធ័ធារាសាស្ត្រ និងសំរេចកិរិតណាមួយដែលអាចទទួលយកបានលើផលិតភាពកសិកម្មដោយនិរន្តរភាព។ PIMD ត្រូវតែរៀបចំឡើងដើម្បីផ្តល់ការអនុគ្រោះ និងសមត្ថភាពគ្រប់គ្រាន់ដល់កសិករប្រើប្រាស់ទឹកដើម្បីដឹកនាំនិងជួយសំរួលឱ្យពួកគេទទួលយកការទទួលខុសត្រូវក្នុងការគ្រប់គ្រងប្រពន្ធ័ធារាសាស្ត្រ។

ដូច្នេះតំរូវការឱ្យយល់ច្បាស់អំពីគោលការណ៏សំខាន់បួនយ៉ាងរបស់ PIMD។ ពិនិត្យគោលការណ៏ ទាំងនេះឡើងវិញ។ (គ្រូឧទ្ទេសនាមគួរសួរសិក្ខាកាមឱ្យឆ្លើយគោលការណ៏ទាំងបួនហើយសរសេរលើក្តារខៀន។ សិក្ខាកាម និងគ្រូឧទ្ទេសនាមរកនិងអធិប្បាយគោលការណ៏ទាំងបួន ហើយរៀបរាប់ពីអ្វីដែលបានផ្លាស់ប្តូរក្នុងគោលការណ៏និមួយៗ)។

១- <u>ការផ្តល់អំណាចឱ្យស.ក.ប.ទ:</u> មានន័យថាអ្នកប្រើប្រាស់ទឹកទាំងអស់ដែលប្រើប្រពន្ធ័ធារាសាស្ត្រត្រូវ ជ្រើសរើសគណៈកម្មាធិការ ស.ក.ប.ទ យល់ព្រមលើធម្មនុញ្ញ និងបទបញ្ញត្តិ ហើយអនុម័តគោលនយោបាយជាគ្រឹះ។ វាមានន័យថា ស.ក.ប.ទ ត្រូវបានបង្កើតជាអង្គភាពស្របច្បាប់ ដោយឯករាជ្យមួយដោយមានអំណាចយ៉ាងពេញលេញក្នុងការធ្វើសេចក្តីសំរេចចិត្តលើការគ្រប់គ្រងប្រពន្ធ័ធារាសាស្ត្រដោយផ្អែកលើគោលការណ៏ "ប្រពន្ធ័ធារាសាស្ត្រមួយ=ប្រពន័គ្រប់គ្រងមួយ" ។

( តើអ្វីដែលផ្លាស់ប្តូរ ? រចនាសម្ពន្ធ័នៃអង្គការ តើបទបញ្ញត្តិអ្វី ដែលវាមាន គោលនយោបាយរបស់ ស.ក.ប.ទ ទំហំ និងព្រំដែនរបស់ ស.ក.ប.ទ ដែលពង្រឹងនយោបាយរបស់ខ្លួន )

២- <u>ស.ក.ប.ទ កំណត់សេវាកម្មទឹក និងជ្រើសរើសអ្នកផ្តល់សេវាកម្មរបស់ខ្លួន</u> - មេដឹកនាំ ស.ក.ប.ទ និងសមាជិកព្រមព្រៀងគ្នាលើប្រភេទសេវាកម្មដែលត្រូវផ្តល់ដោយប្រពន្ធ័ធារាសាស្ត្រហើយ តើត្រូវផ្តល់សេវាកម្មដូចម្តេច។ ស.ក.ប.ទ មានសិទ្ធិជ្រើសរើសនរណា នឹងផ្តល់សេវាកម្មប្រព័ន្ធធារាសាស្ត្ររបស់ខ្លួន និងមានសិទ្ធិចរចាអំពីអណត្តិ

និងលក្ខខណ្ឌសំរាប់ការផ្តល់សេវាកម្ម។ ស.ក.ប.ទ ត្រូវតែងតាំង និងអនុញ្ញាតិឱ្យអ្នកផ្តល់សេវាកម្មអនុវត្តមុខងាររបស់ខ្លួន។ ( តើអ្វីដែលផ្លាស់ប្តូរ ? តើប្រភេទពូជដំណាំណាដែល ស.ក.ប.ទ និមួយៗចង់បាន ? តើ ស.ក.ប.ទ និមួយៗចង់រៀបចំកម្មវិធីផ្តល់ទឹកតាមរបៀបណា?តើកម្មវិធីសកម្មភាពណាសំរាប់ការថែទាំ និងជួសជុលប្រពន្ធ័ធារាសាស្រ្ត? តើ ស.ក.ប.ទ នឹងជ្រើសរើសសមាជិករបស់ខ្លួនដើម្បីផ្តល់សេវាកម្មប្រព័ន្ធធារាសាស្រ្ត ឬតើ ស.ក.ប.ទ នឹងជួលបុគ្គលិកចុះកិច្ចសន្យាជាមួយអ្នកម៉ៅការឬស្នើឱ្យបុគ្គលិករដ្ឋាភិបាលផ្តល់សេវាកម្មខ្លះ ? )

៣- ភាពជាដៃគូនិងគណនីភាពទៅវិញទៅមក - រវាងអ្នកផ្តល់សេវាកម្ម មេដឹកនាំ ស.ក.ប.ទ សមាជិក ស.ក.ប.ទ រដ្ឋាភិបាលនិងអង្គការសេវាកម្មដ៏ទៃ- អ្នកផ្តល់សេវាកម្មបំរើមេដឹកនាំ ស.ក.ប.ទ តាមការអនុញ្ញាត្តិ ប្រសិនបើពុំដូច្នោះទេ អ្នកផ្តល់សេវាកម្មនោះអាចត្រូវបញ្ឈប់ពីតំណែងរបស់ខ្លួន។ គណៈកម្មាធិការ ស.ក.ប.ទ ធ្វើតាមឆន្ទះរបស់សមាជិក ស.ក.ប.ទ ដែលជាអ្នកអនុញ្ញាតិឱ្យខ្លួនក្នុងការជ្រើសតាំងនិងកិច្ចប្រជុំផ្សេងៗ បើពុំដូច្នោះទេ គណៈកម្មាធិការ ស.ក.ប.ទ អាចត្រូវបញ្ឈប់ពីតំណែង។ ស.ក.ប.ទ រដ្ឋាភិបាល និងអង្គការឯទៀត ធ្វើអន្តរសកម្មភាពទៅវិញទៅមកជាដៃគូ មិនមែនជាចៅហ្វាយនិងអ្នកបំរើ។

ការរៀបចំសេវាកម្ម ការបណ្តុះបណ្តាល ។ល។ ត្រូវធ្វើឡើងតាមការយល់ព្រមពីភាគីពាក់ពន្ធ័ទាំងអស់។ ( តើអ្វីដែលផ្លាស់ប្តូរ ? បទបញ្ញត្តិច្បាស់លាស់និងការរៀបចំឱ្យ ស.ក.ប.ទ ប្រើប្រាស់ដើម្បីធានាថាអ្នកផ្តល់សេវាកម្មអនុវត្តតាមមេដឹកនាំ ស.ក.ប.ទ ហើយមេដឹកនាំ ស.ក.ប.ទ អនុវត្តតាមសមាជិក ស.ក.ប.ទ ប្រភេទសេវាកម្មគាំទ្រច្បាស់លាស់ដែលត្រូវផ្តល់ឱ្យ ស.ក.ប.ទ ៉ ស្របតាមសេចក្តីត្រូវការរបស់មូលដ្ឋានរបស់ ស.ក.ប.ទ ៉ អណត្តិ និងលក្ខខណ្ឌ័ច្បាស់លាស់សំរាប់កិច្ចព្រមព្រៀងសេវាកម្ម រវាង ស.ក.ប.ទ និងអ្នកផ្តល់សេវាកម្ម )។

៤- ប្រពន្ធ័គាំទ្រដើម្បីឆ្លើយតបសេចក្តីត្រូវការ ដោយផ្អែកលើការរួមចំណែកក្នុងតំលៃ - រដ្ឋាភិបាលដកខ្លួនថយពីការគ្រប់គ្រងប្រពន្ធ័ធារាសាស្រ្តដោយផ្ទាល់ ហើយផ្តោតតែលើការធ្វើនិយ័តកម្មលើវិស័យទឹកដោយផ្តល់ជំនួយ និងសេវាកម្មគាំទ្រដល់ ស.ក.ប.ទ និងកសាងសមត្ថភាពក្នុង ស.ក.ប.ទ។ ការរៀបចំថ្មីៗត្រូវបានបង្កើតឡើងដើម្បីផ្តល់សេវាកម្មគាំទ្រដោយឈរលើមូលដ្ឋានសំណើពី ស.ក.ប.ទ និងគោលការណ៏ចែករំលែកតម្លៃ។ (តើអ្វីដែលផ្លាស់ប្តូរ? ការលំអិតអំពីការរៀបចំរចនាសម្ពន្ធ័ជាថ្មីនៃនាយកដ្ឋានជំនាញរបស់រដ្ឋាភិបាល ការពង្រាយបុគ្គលិកជាថ្មី សេវាកម្មច្បាស់លាស់ដែលត្រូវផ្តល់ឱ្យ ស.ក.ប.ទ ផ្សេងៗ ) ។

ហេតុអ្វីបានជាមានសារៈសំខាន់ដែល PIMD ត្រូវរួមបញ្ចូលគោលការណ៏សំខាន់ទាំងបួនយ៉ាងរបស់ PIMD? ពីព្រោះត្រូវការសមាសភាពសំខាន់ៗទាំងអស់ដើម្បី :

- បង្កើតការអនុគ្រោះគ្រប់គ្រាន់សំរាប់កសិករ និងរដ្ឋាភិបាលឱ្យគាំទ្រ PIMD
- ធានាគណនីភាពរវាងកសិករ គណៈកម្មាធិការ ស.ក.ប.ទ និងរដ្ឋាភិបាល
- ឱ្យសមត្ថភាពដល់ ស.ក.ប.ទ ដើម្បីទទួលយកការគ្រប់គ្រងប្រពន្ធ័ធារាសាស្រ្តរបស់ខ្លួនដោយមានប្រសិទ្ធិភាព
- កសាងសមត្ថភាពដល់រដ្ឋាភិបាល និងវិស័យឯកជនដើម្បីផ្តល់សេវាកម្មគាំទ្រសមស្រប។

## ៧. តួនាទីរបស់អ្នកសំរបសំរួល និងវិធីសាស្ត្រទាក់ទងដោយមានប្រសិទ្ធិភាព

សមាជិករបស់ក្រុមទ្រទ្រង់ ស.ក.ប.ទ រួមទាំងគ្រូបង្គោលថ្នាក់ស្រុកធ្វើការទាក់ទង និងកសិករក្នុងនាមជាដៃគូ និងជាអ្នកសំរបសំរួលមិនមែនក្នុងនាមជាអ្នកត្រួតពិនិត្យរបស់រដ្ឋាភិបាលទេ។ គោលបំណងគឺដើម្បីជួយក្រុមកសិករឱ្យក្លាយជាក្រុមមានទំនុកចិត្តខ្លួនឯងក្នុងការគ្រប់គ្រងប្រពន្ធ័ធារាសាស្ត្ររបស់ខ្លួន។ ក្នុងការធ្វើទំនាក់ទំនង និងអន្តរសកម្មភាពជាមួយកសិករ ក្រុមទ្រទ្រង់ ស.ក.ប.ទ គួរអនុលោមតាមទស្សនៈវិជ្ជាដូចខាងក្រោមដែលជាអនុសាសន៍ របស់ទស្សនៈវិទូបូរាណចិន Laos Tse គ. ស 700

ទៅជួបប្រជាជន
រស់នៅជាមួយពួកគេ
សិក្សាពីពួកគេ
ស្រឡាញ់ពួកគេ
ចាប់ផ្តើមជាមួយអ្វីដែលពួកគេយល់ដឹង
កសាងជាមួយអ្វីដែលពួកគេមាន
ប៉ុន្តែជាមួយមេដឹកនាំដ៏ល្អបំផុត
នៅពេលការងារត្រូវបានធ្វើចប់សព្វគ្រប់
កាតព្វកិច្ចបានជោគជ័យ
ប្រជាជននឹងនិយាយថា
" យើងបានធ្វើការងារនេះដោយខ្លួនយើង "។

សមាជិកក្រុមទ្រទ្រង់ ស.ក.ប.ទ គួរលើកទឹកចិត្តអ្នកតំណាងកសិករឱ្យរៀបចំនិងចូលរួមក្នុងកិច្ចប្រជុំដែលពេលនេះសមាជិកក្រុមទ្រទ្រង់ ស.ក.ប.ទ ចូលរួមក្នុងឋានៈជាភ្ញៀវ។ សំខាន់បំផុតគឺសមាជិកក្រុមទ្រទ្រង់ ស.ក.ប.ទ ត្រូវលើកទឹកចិត្តកសិករឱ្យនិយាយ គោរពកសិករ និងស្តាប់ពួកគេ។

## ៨. ជំហានក្នុងការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក

ក្រោយពេលដែលសមាជិកក្រុមទ្រទ្រង់របស់ ស.ក.ប.ទ កម្មករធ្វើការហ្វឹងកន្លែង PIMD និងអ្នកជំនួយការ ស.ក.ប.ទ ត្រូវបានជ្រើសរើសនិងបណ្តុះបណ្តាលរួចហើយពួកគេអាចចាប់ផ្តើមសកម្មភាពរៀបចំ ស.ក.ប.ទ កសាងសមត្ថភាពនិងនិងផ្ទេរការគ្រប់គ្រងទៅឱ្យវា។ គួរបង្កើត ស.ក.ប.ទ ដោយឈរលើមូលដ្ឋានព្រំប្រទល់ទឹកក្នុងតំបន់មួយដែលមានប្រភពទឹករួមមួយត្រូវបានប្រើប្រាស់។ គួរបង្កើត ស.ក.ប.ទ តាមសំលេងភាគច្រើនរបស់កសិករប្រើប្រាស់ទឹកទាំងអស់ដែលកាន់កាប់ឬដាំដុះលើដីនៅតំបន់មានទឹកដែលបានបោះឆ្នោតដើម្បីបង្កើតវា។ អ្នកណាដែលបោះឆ្នោតជំទាស់ការបង្កើត ស.ក.ប.ទ ត្រូវតំរូវឱ្យបង់ថ្លៃទឹកខ្ពស់ជាងអ្នកឯទៀត។ ប្រសិនបើគេជំទាស់មិនព្រមបង់ថ្លៃសេវាកម្មទឹក មិនត្រូវផ្តល់ទឹកឱ្យពួកគេទេ។ ខាងក្រោមនេះគឺជាទស្សនៈរួមនៃជំហាន និងកិច្ចការសំរាប់រៀបចំ ស.ក.ប.ទ ការកសាង សមត្ថភាព ការផ្ទេរអំណាច និងការជួសជុល កែលំអរហេដ្ឋារចនាសម្ពន្ធ័។ ក្នុង

ចំណោមកិច្ចការទាំងនេះមួយចំនួនបានធ្វើឡើងក្នុងប្រពន្ធ័សាកល្បងមួយរួចហើយតាមរយៈលំហាត់ និងការចាត់តាំងអនុវត្តជាក្រុមសំរាប់មេរៀនទី ៤ ។

***<u>ជំហានទី ១ : ប្រារព្ធកិច្ចប្រជុំដំបូងនៅគីរីតប្រពន្ធ័ធារាសាស្ត្រ</u>***

កិច្ចការ :

១- ក្រុមទ្រទ្រង់ ស.ក.ប.ទ ប្រារព្ធកិច្ចប្រជុំដើម្បីណែនាំអំពី PIMD

២- ប្រារព្ធកិច្ចប្រជុំវាយតម្លៃមូលដ្ឋានដោយមានការចូលរួមដើម្បីរកបញ្ហាលំបាកនិងឱកាសសំរាប់អភិវឌ្ឍន៍កសិកម្មនិងធារាសាស្ត្រ

៣- ប្រជុំដើម្បីរៀបផែនការជំហានបន្ទាប់ ។

ខាងក្រោមនេះគឺជាប្រធានបទនៃការពិភាក្សាក្នុងកិច្ចប្រជុំណែនាំកសិករប្រើប្រាស់ទឹកមុនពេលបង្កើត ស.ក.ប.ទ :

១-ពិភាក្សាអំពីគោលបំណងនិងទិសដៅរបស់កសិករនិងបញ្ហាលំបាកសំរាប់កសិកម្មនិងជាពិសេសការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ។

២- ពិភាក្សាអំពីជំរើសនានាដើម្បីជំនះបញ្ហាលំបាកក្នុងកសិកម្មនិងជាពិសេសការគ្រប់គ្រងធារាសាស្ត្រ

៣- ក្រុមទ្រទ្រង់ ស.ក.ប.ទ ពន្យល់អំពីគោលនយោបាយ កម្មវិធីរបស់ PIMD និងហេតុផលដែលត្រូវមាន PIMD

៤- ក្រុមទ្រទ្រង់ ស.ក.ប.ទ កសិករនិងមេដឹកនាំមូលដ្ឋានពិភាក្សាគ្នាអំពីអត្ថប្រយោជន៍ កាតព្វកិច្ច និងជំហានក្នុងដំណើរការរៀបចំ ស.ក.ប.ទ

៥- ក្រុមទ្រទ្រង់ ស.ក.ប.ទ កសិករនិងមេដឹកនាំមូលដ្ឋានរៀបផែនការជំហានបន្ទាប់សំរាប់រៀបចំ ស.ក.ប.ទ ។

***<u>ជំហានទី ២ : រកតំបន់សេវាកម្មប្រព័ន្ធធារាសាស្ត្រ និងអនាគតសមាជិក ស.ក.ប.ទ និងអនុវត្តការវាយតម្លៃមូលដ្ឋានដោយមានការចូលរួម</u>***

កិច្ចការ :

- រកព្រំប្រទល់ទឹកសំរាប់បង្កើត ស.ក.ប.ទ និងអនុតំបន់របស់វា
- រកឈ្មោះអនាគតសមាជិក ស.ក.ប.ទ និងអង្គភាពរងនិមួយៗ
- ពិភាក្សានិងធ្វើកិច្ចព្រមព្រៀងបឋមអំពីលក្ខណៈវិនិច្ឆ័យរបស់សមាជិកភាពក្នុង ស.ក.ប.ទ
- អនុវត្ត PRA លើកសិកម្មធារាសាស្ត្រ (អានផ្នែក ៧.២ ខាងក្រោម )
- អនុវត្ត PRA លើការគ្រប់គ្រងប្រពន្ធ័ធារាសាស្ត្រនិងអភិវឌ្ឍន៍ (អានផ្នែក ៧.២ ខាងក្រោម)

***<u>ជំហានទី3 : កសិករយល់ព្រមបង្កើត ស.ក.ប.ទ និងរៀបចំផែនការសកម្មភាពបង្កើតកិច្ចការ :</u>***

- ប្រជុំដើម្បីពិភាក្សានិងធ្វើសេចក្តីសំរេចចិត្តលើការបង្កើត ស.ក.ប.ទ
- រៀបផែនការសកម្មភាព PIMD ដោយមានការចូលរួម

- យល់ព្រមលើសកម្មភាពកសិករដើម្បីបង្កើត ស.ក.ប.ទ
- បោះឆ្នោតជ្រើសតាំងគណៈកម្មាធិការព្រាងលក្ខន្តិកៈ ស.ក.ប.ទ
- ប្រជុំដើម្បីពិភាក្សាអំពីតួនាទីនិងលក្ខណៈសម្បត្តិរបស់អ្នកជំនួយការ ស.ក.ប.ទ
- ការជ្រើសរើសអ្នកជំនួយការ ស.ក.ប.ទ ដោយគណៈកម្មាធិការព្រាងលក្ខន្តិកៈ ស.ក.ប.ទ
- ការបណ្តុះបណ្តាលជាបឋមដល់អ្នកជំនួយការ ស.ក.ប.ទ និងការរៀបចំផែនការ ការងាររបស់គេ

## *ជំហានទី ៤ : កសិកររៀបចំនិងអនុម័តលក្ខន្តិកៈ និងច្បាប់បញ្ញត្តិរបស់ ស.ក.ប.ទ*

កិច្ចការ :

- ណែនាំនិងបណ្តុះបណ្តាលសមាជិករបស់គណៈកម្មាធិការព្រាងអំពីទិដ្ឋភាពផ្លូវច្បាប់ គ្រប់គ្រង និងរៀបចំ ស.ក.ប.ទ និង PIMD
- គណៈកម្មាធិការបញ្ចប់សេចក្តីព្រាងលក្ខន្តិកៈ និងច្បាប់បញ្ញត្តិ
- ធ្វើសេចក្តីព្រាងលក្ខន្តិកៈ និងច្បាប់បញ្ញត្តិត្រូវពិនិត្យឡើងវិញ និងយល់ព្រមដោយក្រុមទ្រទ្រង់ ស.ក.ប.ទ
- ធ្វើសេចក្តីព្រាងលក្ខន្តិកៈ និងច្បាប់បញ្ញត្តិត្រូវពិភាក្សានិងកែតំរូវឡើងវិញក្នុងកិច្ចប្រជុំទូទៅរបស់អនាគតសមាជិក
- លក្ខន្តិកៈដែលបានកែតំរូវ និងព្រមព្រៀងហើយត្រូវចុះហត្ថលេខាដោយអនាគតសមាជិក ស.ក.ប.ទ ទាំងអស់
- ចុះបញ្ជីសមាជិក

ខាងក្រោមនេះគឺជាខ្លឹមសារនានាដែលតែងតែបញ្ចូលក្នុងលក្ខន្តិកៈ ស.ក.ប.ទ

១- សេចក្តីថ្លែងការណ៍បេសកកម្ម ស.ក.ប.ទ ( តើអ្វីជាគោលបំណង និងវិសាលភាពរបស់ ស.ក.ប.ទ)

២- រចនាសម្ពន្ធ័ & មុខងារជាមូលដ្ឋាន (តើអ្វីជាមុខងារជាមូលដ្ឋានរបស់ ស.ក.ប.ទ? តើអ្វីជារចនាសម្ពន្ធ័ស្ថាប័ននិងគោលជំហររបស់ ស.ក.ប.ទ ?)

៣- ឋានៈផ្លូវច្បាប់ & មូលដ្ឋានអជ្ញាធរ (តើអ្វីជា ឋានៈផ្លូវច្បាប់ អំណាចផ្លូវច្បាប់និងកំរិតនៃអជ្ញាធររបស់ ស.ក.ប.ទ ?)

៣- ដែនសមត្ថកិច្ច(តើអ្វីជាព្រំប្រទល់នៃប្រពន្ធ័ធារាសាស្ត្រនិងអ្វីជារចនាសម្ពន្ធ័ត្រូវបញ្ចូលក្នុងសមត្ថកិច្ចរបស់ ស.ក.ប.ទ ?)

៥- លក្ខណៈវិនិច្ឆ័យសំរាប់សមាជិកភាព (តើនរណាជាសមាជិករបស់ ស.ក.ប.ទ និងតើគេត្រូវមានលក្ខខណ្ឌ័អ្វីដើម្បីក្លាយជាសមាជិក?)

៦- ការទទួលខុសត្រូវ និងសិទ្ធិជាមូលដ្ឋានរបស់ ស.ក.ប.ទ (តើអ្វីជាកាទទួលខុសត្រូវ និងសិទ្ធិជាមូលដ្ឋានរបស់ ស.ក.ប.ទ ជាអង្គភាពប្រមូលផ្តុំមួយ និងតើអ្វីជាសិទ្ធិនិងការទទួលខុសត្រូវរបស់សមាជិកម្នាក់ៗ?)

៧- រចនាសម្ពន្ធ័ដឹកនាំ (តើតំណែងដឹកនាំអ្វីនៅក្នុង ស.ក.ប.ទ ?)

៨- វិធីសាស្ត្រសំរាប់ធ្វើវិសោធនកម្មលក្ខន្តិកៈរបស់ ស.ក.ប.ទ (តើអ្វីជាដំណើរការសំរាប់បន្ថែមឬផ្លាស់ប្តូរលក្ខន្តិកៈរបស់ ស.ក.ប.ទ ?) ច្បាប់បញ្ញត្តិរបស់ ស.ក.ប.ទ ជាបញ្ញត្តិប្រតិបត្តិការជាក់ច្បាស់សំរាប់ការអនុវត្តន៍លក្ខន្តិកៈ ស.ក.ប.ទ ។

ខាងក្រោមនេះជាខ្លឹមសារដែលតែងតែបញ្ចូលក្នុងច្បាប់បញ្ញត្តិរបស់សហគមន៍អ្នកប្រើប្រាស់ទឹកឬ ស.ក.ប.ទ

១- និតិវិធីសំរាប់ទទួល និងបណ្តេញសមាជិក

២- តំណែងនិងមុខងារដឹកនាំ

៣- និតិវិធីសំរាប់ជ្រើសរើសនិងដកតំណែងមេដឹកនាំ ការកាន់កាប់ការិយាល័យ

៤- អធិប្បាយអំពីបទបញ្ញត្តិ និងគោលបំណងនៃការផ្តល់ទឹកនិងថែទាំ

៥- បទបញ្ញត្តិនិងការដាក់ទណ្ឌកម្មអំពីថ្លៃឈ្នួលសេវាកម្មប្រព័ន្ធធារាសាស្ត្រ

៦- រចនាសម្ព័ន្ធនៃការធ្វើសេចក្តីសំរេចចិត្តលើការសំរេចគោលនយោបាយនិងកលវិធី

៧- និតិវិធីក្នុងការចូលកិច្ចសន្យា

៨- ពិធីការសំរាប់បង្កើតសហពន្ធ័និងទំនាក់ទំនងខាងក្រៅ

៩- និតិវិធីសំរាប់ធ្វើវិសោធនកម្មច្បាប់បញ្ញត្តិ

ក្រុមទ្រទ្រង់ ស.ក.ប.ទ គួរចងចាំថាលក្ខន្តិកៈ និងច្បាប់បញ្ញត្តិ ស.ក.ប.ទ ជាឯកសារបំរុងជាមុនរបស់មេដឹកនាំនិងសមាជិក ស.ក.ប.ទ ។ ឯកសារទាំងនេះគួរផ្អែកតាមតំរូវការមូលដ្ឋាននិងចំណូលចិត្តរបស់កសិករខ្លួនឯងដែលជួនកាលខុសពីទំរង់ស្តង់ដាដែលរៀបរាប់ខាងលើ ។ ខ្លឹមសារខាងលើគ្រាន់តែជាការណែនាំតែប៉ុណ្ណោះ ។ ខ្លឹមសារជាក់លាក់គួរកំណត់និងបញ្ចូលដោយកសិករដោយខ្លួនឯង ដោយមានជំនួយពីក្រុមទ្រ ទ្រង់ ស.ក.ប.ទ ។

## ***ជំហានទី ៥ : កសិករបង្កើត ស.ក.ប.ទ និងជ្រើសរើសមេដឹកនាំ***

កិច្ចការ :

- បោះឆ្នោតជ្រើសរើសអ្នកតំណាង ក.ក.ប.ទ (នៅកំរិតប្លុកហ្វ៊ីងកន្លែង)
- បោះឆ្នោតជ្រើសរើសអ្នកតំណាងគណៈកម្មាធិការប្រឡាយទី ២ (ប្រសិនបើត្រូវការ)
- បោះឆ្នោតជ្រើសរើសគណៈកម្មាធិការ ស.ក.ប.ទ (ជ្រើសរើសប្រធាននិងមន្ត្រីឯទៀតនៅកំរិតប្រពន្ធ័ធារាសាស្ត្រ)
- ចុះបញ្ជី ស.ក.ប.ទ នៅក្នុងក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងធនធានទឹក និងឧតុនិយម ទទួលស្គាល់លក្ខន្តិកៈនិងច្បាប់បញ្ញត្តិ(នេះបង្កើតនូវការទទួលស្គាល់ស្របច្បាប់ជាផ្លូវការ) ។

## ***ជំហានទី ៦ : កសាងសមត្ថភាព ស.ក.ប.ទ ដើម្បីរៀបចំផែនការសេវាកម្មប្រព័ន្ធធារាសាស្រ្ត***

កិច្ចការ :

- បណ្តុះបណ្តាលមន្ត្រី ស.ក.ប.ទ អំពីការផ្តល់ទឹកការថែទាំសំណង់រៀបផែនការសេវាកម្មប្រព័ន្ធធារាសាស្រ្ត ការគ្រប់គ្រងថវិការ និងហិរញ្ញវត្ថុ (ភាគច្រើនបំផុតនៃការបណ្តុះបណ្តាលគួរធ្វើតាមររៀបណែនាំ និងបង្ហាត់បង្រៀនលើកន្លែងការងារ ដោយក្រុមទ្រទ្រង់ ស.ក.ប.ទ និងគ្រូបង្គោលដំទៃទៀត )
- ធ្វើបញ្ជីសារពើពណ្ណដាលំអិតអំពីហេដ្ឋារចនាសម្ពន្ធ័ទាំងអស់ក្នុងប្រពន្ធ័ធារាសាស្ត្រនិងការវាយតម្លៃលក្ខខណ្ឌ័ដំណើរការនាពេលបច្ចុប្បន្នរបស់វា ។
- រួមជាមួយក្រុមទ្រទ្រង់ ស.ក.ប.ទ រៀបផែនការសេវាកម្មធារាសាស្ត្រសំរាប់ស្ថានភាពបច្ចុប្បន្ន (នោះគឺថាមុនពេលជួសជុលនិងកែលំអរក្នុងហេដ្ឋារចនាសម្ពន្ធ័នៃប្រពន្ធ័ធារាសាស្ត្រ) ។
- ដោយមានជំនួយពីក្រុមទ្រទ្រង់ ស.ក.ប.ទ កំណត់គោលបំណងនៃការអភិវឌ្ឍន៏កសិកម្មរបស់ ស.ក.ប.ទ
- ក្នុងវិធីសាស្ត្រទូទៅ ស.ក.ប.ទ ក៏តំរូវការជួសជុលនិងកែលំអរហេដ្ឋារចនាសម្ពន្ធ័នៃប្រពន្ធ័ធារាសាស្ត្រ
- ដោយមានជំនួយពីក្រុមទ្រទ្រង់ ស.ក.ប.ទ រៀបចំពង្រាងផែនការសេវាកម្មប្រព័ន្ធធារាសាស្ត្រសំរាប់ប្រមើល មើលស្ថានភាពក្រោយពេលជួសជុល និងកែលំអរក្នុងហេដ្ឋារចនាសម្ពន្ធ័នៃប្រពន្ធ័ធារាសាស្ត្រ ដែលនឹងត្រូវធ្វើរួមមានការប៉ាន់ប្រមាណតម្លៃសំរាប់ការអនុវត្តផែនការសេវាកម្មប្រព័ន្ធធារាសាស្ត្រ និងការជួសជុលកែលំអរម្តងម្កាល
- ជ្រើសរើសឬតែងតាំងបុគ្គលិកគ្រប់គ្រង ស.ក.ប.ទ
- បណ្តុះបណ្តាលបន្ថែមទៀតដល់មន្ត្រីនិងបុគ្គលិក ស.ក.ប.ទ ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ។

## ***ជំហានទី ៧ : ស.ក.ប.ទ អនុម័ត និងអនុវត្តផែនការសេវាកម្មប្រព័ន្ធធារាសាស្ត្រដំបូង***

កិច្ចការ :

- សំរេចផែនការសេវាកម្មប្រព័ន្ធធារាសាស្ត្រ ហើយផ្តល់ថវិកាដោយគណៈកម្មាធិការ ស.ក.ប.ទ (ដោយមានជំនួយពីក្រុមទ្រទ្រង់ )
- គណនាថ្លៃឈ្នួលសេវាកម្មធារាសាស្ត្រ និងកំណត់និតិវិធីយកថ្លៃប្រមូល ការគ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុ (ថ្លៃឈ្នួលអាចជាប្រាក់ ជាទិន្នផល ការរួមវិភាគទានពលកម្ម ឬសំភារៈ )
- ពិភាក្សានិងព្រមព្រៀងលើផែនការសេវាកម្មប្រព័ន្ធធារាសាស្ត្រ ថវិកា និងថ្លៃឈ្នួលក្នុងកិច្ចប្រជុំរួម ស.ក.ប.ទ
- ស.ក.ប.ទ បើកគណនីធនាគារ (ឬរៀបចំទុកដាក់និងគ្រប់គ្រងមូលនិធិដែលបានប្រមូល)
- ការប្រមូលថ្លៃឈ្នួលសេវាកម្មប្រព័ន្ធធារាសាស្ត្រ
- ក្រុមទ្រទ្រង់ ស.ក.ប.ទ ជួយ ស.ក.ប.ទ (បើសិនត្រូវការ) ក្នុងការអនុវត្តន៏ផែនការសេវាកម្មធារាសាស្ត្រលើកទី ១ (សំរាប់រយៈពេលមួយឆ្នាំ )

**(អានមេរៀនទី ៤ វគ្គទី១ សំរាប់ពត៌មានអំពីរចនាសម្ពន្ធ័ និងខ្លឹមសារនៃផែនការសេវាកម្មប្រព័ន្ធធារាសាស្ត្រ ) ។**

***<u>ជំហានទី៨ :រៀបចំ និងអនុម័តកិច្ចព្រមព្រៀងផ្ទេរការគ្រប់គ្រង (ឬវិញ្ញាបនប័ត្របញ្ជាក់អំណាចគ្រប់គ្រង)</u>***

កិច្ចការ :

- គណៈកម្មាធិការគ្រប់គ្រង ស.ក.ប.ទ និងក្រុមទ្រទ្រង់ ស.ក.ប.ទ ពិភាក្សាគ្នាអំពីគំរូកិច្ចព្រមព្រៀងការគ្រប់គ្រង (ឬវិញ្ញាបនប័ត្របញ្ជាក់អំណាចគ្រប់គ្រងរបស់ ស.ក.ប.ទ )
- ពង្រាងកិច្ចព្រមព្រៀងផ្ទេរត្រូវរៀបចំ ពិភាក្សា កែតំរូវនិងយល់ព្រមដោយគណៈកម្មាធិការ ស.ក.ប.ទ ក្រុមទ្រទ្រង់ ស.ក.ប.ទ និងកិច្ចប្រជុំទូទៅរបស់ ស.ក.ប.ទ
- ក្រោយពេលពេញមួយឆ្នាំនៃការអនុវត្តផែនការសេវាកម្មធារាសាស្ត្រទីមួយដោយជោគជ័យរួច មកកិច្ចព្រមព្រៀងផ្ទេរការគ្រប់គ្រង (ឬវិញ្ញាបនប័ត្របញ្ជាក់ការគ្រប់គ្រងរបស់ ស.ក.ប.ទ) ត្រូវចុះហត្ថលេខាដោយគណៈកម្មាធិការគ្រប់គ្រង ស.ក.ប.ទ និងក្រសួងធនធានទឹក និងឧតុនិយម

ក្នុងកម្ពុជាប្រពន្ធ័ភាគច្រើនកំពុងត្រូវបានគ្រប់គ្រងដោយកសិករនិងអជ្ញាធរមូលដ្ឋាន។ ដូច្នេះកិច្ចព្រមព្រៀងផ្ទេរការគ្រប់គ្រងឬវិញ្ញាបនប័ត្របញ្ជាក់ការគ្រប់គ្រងរបស់ ស.ក.ប.ទ មានប្រយោជន៏ណាស់ដើម្បីបំភ្លឺ និងឱ្យមតិសាធារណៈទទួលស្គាល់ជាផ្លូវការថា ស.ក.ប.ទ មានការទទួលខុសត្រូវ និងអំណាចក្នុងការត្រួតពិនិត្យការគ្រប់គ្រងសំណង់ប្រព័ន្ធធារាសាស្ត្រ ។កិច្ចព្រមព្រៀងផ្ទេរឬវិញ្ញាបនប័ត្របញ្ជាក់អំណាចគ្រប់គ្រងរបស់ ស.ក.ប.ទ បញ្ជាក់អំពីការបែងចែកសិទ្ធិ ការទទួលខុសត្រូវ កាតព្វកិច្ចនិងអំណាចនាពេលអនាគតរវាង ស.ក.ប.ទ និងរដ្ឋាភិបាល ។

***<u>ខាងក្រោមនេះគឺជាខ្លឹមសារនៃកិច្ចព្រមព្រៀងផ្ទេរការគ្រប់គ្រង :</u>***

១-តំបន់សេវាកម្មនិងលក្ខណៈវិនិច្ឆ័យសមាជិកភាពរបស់ ស.ក.ប.ទ

២- ធ្វើបញ្ជីសារពើពណ្ឌនៃហេដ្ឋារចនាសម្ពន្ធ័ និងសំភារៈតាមកាលៈទេសៈ (ប្រសិនមាន ) ហើយបំភ្លឺអំពីកម្មសិទ្ធិភាពឬសិទ្ធិប្រើប្រាស់រយៈពេលវែងក្នុងរចនាសម្ពន្ធ័ដែលត្រូវផ្ទេរទៅឱ្យស.ក.ប.ទ

៣- សិទ្ធិជាមូលដ្ឋាន អំណាចនិងកាតព្វកិច្ចរបស់ ស.ក.ប.ទ

៤- សិទ្ធិ អំណាចនិងកាតព្វកិច្ចរបស់រដ្ឋាភិបាលចំពោះ ស.ក.ប.ទ (ដូចជាត្រូវធ្វើនិយ័តកម្ម កសាងសមត្ថភាព និងផ្តល់សេវាកម្មគាំទ្រ)

៥- និតិវិធីសំរាប់ដោះស្រាយជម្លោះ

៦- គោលបំណងនិងខ្លឹមសារនៃផែនការសេវាកម្មប្រព័ន្ធធារាសាស្ត្រ (និងកាតព្វកិច្ចដើម្បីរៀបចំវា)

៧- គោលបំណង និតិវិធីនិងសារៈសំខាន់នៃសេវាកម្មការគ្រប់គ្រងធារាសាស្ត្រ

៨- ពិធីការសំរាប់ទំនាក់ទំនងរវាង ស.ក.ប.ទ និងរដ្ឋាភិបាល

៩- អណត្តិនិងលក្ខខណ្ឌ័សំរាប់ការផ្ទេរដែលត្រូវសើរើឡើងវិញ

១០- និតិវិធីសំរាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងផ្ទេរ

## ***ជំហានទី ៩ :ការជួសជុល និងកែលំអរហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ***

កិច្ចការ :

- រកកន្លែងជួសជុលនិងកែលំអរដោយធ្វើការសិក្សាជាមុននិងប៉ាន់ប្រមាណតម្លៃដោយមានការចូលរួម
- ស.ក.ប.ទ និងក្រុមទ្រទ្រង់ ស.ក.ប.ទ រៀបចំពិភាក្សាកែតំរូវនិងយល់ព្រមលើពង្រាងសំរាប់កែលំអរ និងផែនការសំរាប់អនុវត្ត (ដែលរួមមានការផ្តល់ហិរញ្ញប្បទានរួម )
- សំរាប់ការជួសជុលទ្រង់ទ្រាយមធ្យមដែល ស.ក.ប.ទ ត្រូវការជំនួយ ស.ក.ប.ទ ត្រូវរៀបចំសំណើ សុំជំនួយសំរាប់ជួសជុលនិងកែលំអរហើយដាក់ជូនមូលនិធិកែលំអរប្រព័ន្ធធារាសាស្ត្រថ្នាក់ខេត្ត

ដើម្បីពិនិត្យ

- ប្រសិនបើសំណើរនោះត្រូវបានទទួលការយល់ព្រម ជំនួយត្រូវផ្តល់ទៅឱ្យស.ក.ប.ទ ហើយ ស.ក.ប.ទ ត្រូវអនុវត្តការជួសជុលនិងកែលំអរជាបន្ទាន់ ។
- សំរាប់ការស្តារទ្រង់ទ្រាយធំឬការងារជួសជុលបន្ទាន់ត្រូវរៀបចំនិងផ្តល់មូលនិធិពិសេស ប៉ុន្តែត្រូវ មានភាពស៊ីសង្វាក់ជាមួយគោលការណ៏ PIMD
- ក្រសួងធនធានទឹក និងឧតុនិយម អនុវត្តតួនាទីរបស់ខ្លួនក្នុងការសាងសង់(បញ្ឈប់ហិរញ្ញប្បទាន &អាស្រ័យលើការរួមវិភាគទានរបស់កសិករ )
- ត្រូវសាកល្បងហេដ្ឋារចនាសម្ពន្ធ័ដែលជួសជុលរួចបន្ទាប់មកគណៈកម្មាធិការ ស.ក.ប.ទ ត្រូវចុះ ហត្ថលេខាព្រមព្រៀងទទួលដើម្បីគ្រប់គ្រង ។

ជាសំខាន់ត្រូវសង្កត់ធ្ងន់ថាការជួសជុល និងកែលំអរជាក់លាក់លើហេដ្ឋារចនាសម្ពន្ធ័ (នោះគឺថាធ្វើជាមួយ រដ្ឋាភិបាល ឬ ម្ចាស់ជំនួយ ) អាចធ្វើបានតែនៅក្រោយពេល១) ស.ក.ប.ទ ត្រូវបានបង្កើតឡើងរួចជាស្រេច ២) ការផ្ទេរការគ្រប់គ្រងត្រូវបានផ្ទេររួចជាស្រេចនិង ៣) ស.ក.ប.ទ មានគោលបំណងជាក់លាក់លើសេវាកម្ម ប្រព័ន្ធធារាសាស្ត្រ និងកសិកម្ម។ ធ្វើដូចនេះដើម្បីជួយសំរួលឱ្យ ស.ក.ប.ទ អាចដំណើរការត្រួតពិនិត្យបានល្អ និងអាចធានាថាការងារកែលំអរជារូបវន្តជាការងារធ្វើឡើងតាមសំណើ ហើយនឹងត្រូវរួមបញ្ចូលនូវវិនិយោគសម ស្រប ដោយ ស.ក.ប.ទ ។

## ***ជំហានទី ១០ : បន្តការកសាងសមត្ថភាព និងផ្តល់សេវាកម្មគាំទ្រ***

កិច្ចការ :

- បណ្តុះបណ្តាលម្តងម្កាលដល់ ស.ក.ប.ទ ដោយក្រុមទ្រទ្រង់ ស.ក.ប.ទ និងដោយអង្គភាពវិស័យឯកជន
- សវនកម្មសេវាកម្មធារាសាស្ត្រប្រចាំឆ្នាំ(ដើម្បីពិនិត្យការអនុវត្តន៏របស់ ស.ក.ប.ទ និងរដ្ឋាភិបាល)
- កិច្ចព្រមព្រៀងសេវាកម្ម (ដែលសំណង់គ្រប់គ្រងរួមគ្នាដោយ ស.ក.ប.ទ និងរដ្ឋាភិបាលឬអ្នកមៅការ )
- រដ្ឋាភិបាលបញ្ឈប់ការឧបត្ថម្ភធនសំរាប់ផែនការសេវាកម្មប្រព័ន្ធធារាសាស្ត្រ (ប្រសិនជាអាចអនុវត្តបាន )

- បង្កើតនិងដាក់ឱ្យមានដំណើរការនូវមូលនិធិកែលំអរប្រព័ន្ធធារាសាស្ត្រថ្នាក់ខេត្តឬតំបន់ក្នុងទីកន្លែងសាកល្បងគំរោង
- វាយតម្លៃ PIMD ។

ខាងក្រោមនេះគឺជាការបណ្តុះបណ្តាល និងការកសាងសមត្ថភាពបន្ថសំរាប់ ស.ក.ប.ទ:

១- របៀបមេដឹកនាំធ្វើទំនាក់ទំនងជាមួយកសិករ

២- របៀបមេដឹកនាំរៀបផែនការ&ចូលរួមក្នុងកិច្ចប្រជុំ លើកទឹកចិត្តការពិភាក្សាឱ្យមានប្រសិទ្ធិភាព កសាងការព្រមព្រៀងរួមដើម្បីធ្វើសេចក្តីសំរេចចិត្ត

៣- រៀបចំខ្លឹមសារលើមាត្រាសំរាប់ច្បាប់បញ្ញត្តិរបស់សហគមន៍

៤- រក្សាកំណត់ហេតុនៃកិច្ចប្រជុំ និងសកម្មភាពនានា

៥- រៀបចំនិងអនុវត្តផែនការ O&M តាមរដូវ

៦- រកជំរើសដើម្បីប្រមូលធនធានសំរាប់គាំទ្រ O&M (ពលកម្ម សំភារៈ ការបង់សេវាកម្មប្រព័ន្ធធារាសាស្ត្រ )

៧- គ្រប់គ្រងហិរញ្ញវត្ថុ (ការប្រមូលសេវាកម្មប្រព័ន្ធធារាសាស្ត្រ គណនីធនាគារ សំរេចតើត្រូវប្រើថវិកាប៉ុន្មានរក្សា កំណត់ហេតុហិរញ្ញវត្ថុ ថ្លឹងថ្លែងដើម្បីការពារកុំឱ្យមានការប្រើប្រាស់មូលនិធិខុស )

៨- ពង្រឹងបទបញ្ញត្តិដោយដាក់ទណ្ឌកម្ម &ដោះស្រាយជម្លោះនិងបញ្ហាផ្លូវច្បាប់ដ៏ទៃទៀត

៩- វាយតម្លៃបច្ចេកទេស& ប៉ាន់ប្រមាណតម្លៃលើការជួសជុលនិងកែលំអរខ្នាតតូច

១០- រៀបចំសំណើរសុំជំនួយឥតសំណងពីមូលនិធិជួសជុលនិងកែលំអរប្រព័ន្ធធារាសាស្ត្រ

១១- ផ្សព្វផ្សាយកសិកម្ម

**១២-** អភិវឌ្ឍបណ្តាញកសិ-ពាណិជ្ជកម្មនិងទីផ្សារថ្មីៗ ។

## ៩. សវនកម្មការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ

បន្ទាប់ពីផែនការសេវាកម្មធារាសាស្ត្រ (ISP) ត្រូវបានអនុម័តនិងអនុវត្តរួចហើយ គួរធ្វើសវនកម្មគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ (IMA) ប្រចាំឆ្នាំលើសំណង់ប្រព័ន្ធធារាសាស្ត្រនិមួយៗដែលបានផ្ទេរជាផ្លូវការឱ្យ ស.ក.ប.ទ គ្រប់គ្រង។ IMA គួរពិនិត្យភាពស៊ីសង្វាក់គ្នារវាង ស.ក.ប.ទ និងរដ្ឋាភិបាលជាមួយអណត្តិ និងលក្ខខណ្ឌ នៃកិច្ចព្រមព្រៀងផ្ទេរ (ឬការទទួលស្គាល់អំណាច អានខាងក្រោម) និងគំរិតការអនុវត្តផែនការសេវាកម្មប្រព័ន្ធធារាសាស្ត្រ។ សវនកម្មនេះ ក៏នឹងធ្វើលើទិដ្ឋភាពរៀបចំបច្ចេកទេស និងហិរញ្ញវត្ថុរបស់ ស.ក.ប.ទ និងស្ថាប័នរដ្ឋាភិបាលដែលពាក់ពន្ធ័។ IMA នឹងពិនិត្យស្ថាប័នរដ្ឋាភិបាលដែលពាក់ពន្ធ័តែលើកាតព្វកិច្ចនិយ័តកម្ម លើវិស័យនេះការផ្តល់សេវាកម្មគាំទ្រ បច្ចេកទេស និងហិរញ្ញវត្ថុដល់ ស.ក.ប.ទ និងការបំពេញកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចព្រមព្រៀងសេវាកម្មប្រព័ន្ធ ធារាសាស្ត្រជាផ្លូវការដែលបានធ្វើឡើងជាមួយ ស.ក.ប.ទ។

សមាជិកនៃគណៈកម្មាធិការតូចៗក្នុង ស.ក.ប.ទ សមាជិកក្រុមទ្រទ្រង់ ស.ក.ប.ទ ដែលបានជ្រើសរើស និងមន្ត្រីម្នាក់មកពីនាយកដ្ឋានសវនកម្មរបស់រដ្ឋាភិបាលគួរបង្កើតក្រុម IMA មួយ ។ គំហើញជាវិជ្ជមានពីការធ្វើសវនកម្មគួរឱ្យលទ្ធផលជាភាពត្រឹមត្រូវរបស់ ស.ក.ប.ទ នាពេលអនាគតដើម្បីទទួលជំនួយពីរដ្ឋាភិបាលសំរាប់ការជួសជុល និងកែលំអរ ។ គំហើញជាអវិជ្ជមានគួរឱ្យលទ្ធផលជាទណ្ឌកម្ម ដូចជាភាពមិនត្រឹមត្រូវជាបណ្ដោះអាសន្នរបស់ ស.ក.ប.ទ ហើយត្រូវផ្អាកការផ្តល់ជំនួយពីរដ្ឋាភិបាលសិន រហូតដល់បញ្ហាដែលកើតឡើងនោះត្រូវបានដោះស្រាយ ។

## ១០. លំហាត់ជាក្រុមសំរាប់មេរៀនទី ៥ វគ្គទី ១

### លំហាត់ទី ១ : ការរៀបចំរបាយការណ៏

គ្រូឧទ្ទេសនាមតែងតាំងសិក្ខាកាមពីរនាក់ឱ្យធ្វើជាអ្នករាយការណ៏សំរាប់មេរៀនទី ៥ វគ្គទី ១។ ពួកគេនឹងសរសេរសង្ខេបអំពីចំណុចសំខាន់ៗក្នុងបវកថានិងលំហាត់ដោយមានការចូលរួម។ ពួកគេគួររៀបចំរបាយការណ៏ក្នុងរយៈ ពេលមួយថ្ងៃបន្ទាប់ពីវគ្គទី ១ ចប់សព្វគ្រប់ ។

### លំហាត់ទី ២ : ការដើរតួសំដែងជាវិស្វករសង្គមនិងអ្នកសំរបសំរួល

ជំហានទី ១: ក្រោយពីបង្ហាញប្រធានបទនៃការបណ្ដុះបណ្ដាលអំពីតួនាទីរបស់អ្នកសំរបសំរួលនិងវិធីសាស្ត្រទាក់ទងរួចហើយគ្រូឧទ្ទេសនាមរៀបចំឆាកដើរតួសំដែងដោយឱ្យសិក្ខាកាមពីរនាក់ដើរតួជាវិស្វករ សង្គម និងពីរនាក់ទៀតជាកសិករ ។

ជំហានទី ២: តួសំដែងទាំងនេះពិភាក្សាគ្នាអំពីការអនុគ្រោះរបស់កសិករដើម្បីរៀបចំនិងមូលហេតុដែលត្រូវបង្កើត ស.ក.ប.ទអ្នកដើរតួជាកសិករបញ្ចេញប្រតិកម្មដូចកសិករពិតដែលមានប្រតិកម្មទល់ និងវិធីសាស្ត្រវិស្វករសង្គមដូច្នេះដែរ ។

ជំហានទី ៣: បន្ទាប់ពីឆាកនេះចប់ ត្រូវជ្រើសសិក្ខាកាមពីរនាក់ទៀតឱ្យដើរតួជាអ្នកសំរបសំរួល ហើយពីរនាក់ទៀតជាកសិករ ។ ពួកគេពិភាក្សាគ្នាអំពីការអនុគ្រោះរបស់កសិករដើម្បីរៀបចំ និងមូលហេតុដែលត្រូវបង្កើត ស.ក.ប.ទ ប៉ុន្តែពួកគេប្រើវិធីសាស្ត្រទំនាក់ទំនងគ្នាផ្សេងពីមុន (ជាអ្នកសំរបសំរួល) ដែល "កសិករ" ផ្សេងពីមុន ។

ជំហានទី ៤: ការសំដែងតួបន្តដដែលទៀតដោយឱ្យសិក្ខាកាមឯទៀតធ្វើជាអ្នកសំរបសំរួល ។

ជំហានទី ៥: សិក្ខាកាមទាំងអស់ពិភាក្សាគ្នាអំពីការសំដែងតួ និងមេរៀន ។

### លំហាត់ទី ៣ : ការពិនិត្យឡើងវិញ

ជំហានទី១: នៅពេលបញ្ចប់វគ្គទី១ មេរៀនទី៥ គ្រូឧទ្ទេសនាមស្នើសិក្ខាកាមឱ្យរៀបរាប់ចំណុចសំខាន់ៗដែលគេបានសិក្សាក្នុងវគ្គទី ១ ។

ជំហានទី ២: អ្នករាយការណ៏អានរបាយការណ៏សង្ខេបសំរាប់វគ្គទី 1

ជំហានទី ៣: គ្រូឧទ្ទេសនាមសួរសិក្ខាកាមប្រសិនបើគេចង់កែតំរូវឬសំណើបន្ថែមក្នុងរបាយការណ៏ប្រសិន បើមាន

ជំហានទី ៤ : អ្នករាយការណ៍កត់ត្រាសំណើហើយកែតំរូវរបាយការណ៍សំរាប់វគ្គទី 1 បើសិនត្រូវការ

## ១១. សង្ខេបមេរៀនទី ៥ វគ្គទី ១

( អ្នករាយការណ៍បង្ហាញរបាយការណ៍ពីចំណុចសំខាន់ៗដែលបានលើកឡើងក្នុងការពិភាក្សា និងលំហាត់។ សិក្ខាកាមទាំងអស់ធ្វើការកែតំរូវឬបន្ថែមតាមត្រូវការ )។

**ចប់មេរៀនទី ៥ វគ្គទី ១**

## <u>វគ្គទី ២ : ការអនុវត្តន៏លំហាត់តាមក្រុម</u>

ការចាត់តាំងនេះគួរធ្វើដោយក្រុមទ្រទ្រង់ ស.ក.ប.ទ និមួយៗ។

កិច្ចការទី ១: រៀបចំកត់ត្រាចំណុចផ្សេងៗហើយចេញពីសេចក្តីព្រៀងសំរាប់ភ្នាក់ងារនិមួយៗដែលពាក់ពន្ធ័ក្នុងការអនុវត្តន៍ PIMD នៅថ្នាក់ស្រុក និងខេត្ត អំពីរបៀបដែលទីភ្នាក់ងារ និងរៀបចំការអនុគ្រោះសមស្រប និងវិធានការមានគណនីភាពដើម្បីធានាថាបុគ្គលិករបស់ខ្លួនធ្វើការលើ PIMD ប្រកបដោយប្រសិទ្ធិភាព

កិច្ចការទី ២ :រៀបចំផែនការលំអិតពីរបៀបដែលក្រុមទ្រទ្រង់ ស.ក.ប.ទ នឹងហើយធ្វើការជាបណ្តោះអាសន្នជាមួយតំណាងកសិករ ដើម្បីជួយរៀបចំដំណើរការ។

កិច្ចការទី ៣: រៀបចំសេចក្តីព្រៀងរបៀបវារៈសំរាប់កិច្ចប្រជុំសំខាន់ៗជាមួយកសិករដើម្បីរៀបចំ ស.ក.ប.ទ។ របៀបវារៈនេះរួមមានការអធិប្បាយអំពីវិធីសាស្ត្រទំនាក់ទំនងដែលត្រូវប្រើប្រធានបទដែលត្រូវពិភាក្សានិងលទ្ធផលដែលរំពឹងទុក។

កិច្ចការទី ៤ : រៀបចំសេចក្តីព្រៀងផែនការ ការងាររយៈពេលពីរឆ្នាំរបស់ក្រុមទ្រទ្រង់ ស.ក.ប.ទ ។

កិច្ចការទី ៥: រៀបចំហើយបង្ហាញរបាយការណ៍ដល់លេខាធិការដ្ឋានជាតិ (ដែលផ្តល់មតិ ) និងសំរេចលើរបាយការណ៍។

ក្រុមទ្រទ្រង់នឹងបង្ហាញរបាយការណ៍នេះសំរាប់ការពិភាក្សានៅពេលចាប់ផ្តើមមេរៀនទី ៦។

